របៀបរៀបចំរបាយការណ៍ស្រាវជ្រាវតាម

APA STYLE (7th EDITION)



មាស

របៀបរៀបចំឯកសារស្រាវជ្រាវតាម

APA STYLE 7th Edition

*ស្បៀវភៅនេះសរសេរឡើងសម្រាប់គោលបំណងចែករំលែក
ចំណេះដឹងដោយសេរី និងឥតគិតថ្លៃប៉ុណ្ណោះ។

* រាល់រូបភាពស្បៀវភៅ ឬអត្ថបទស្រាវជ្រាវ មិនមែនជាកម្មសិទ្ធ
របស់អ្នកនិពន្ធឡើយ រូបភាពទាំងនេះត្រូវបានប្រើប្រាស់ដើម្បីរំលេច
ជាឧទាហរណ៏ប៉ុណ្ណោះ។

* ស្បៀវភៅនេះលោកអ្នកអាចយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេង
ៗបានដោយសេរី។

@ Meas 2025

អារម្ភកថា

ការរៀបចំឯកសារស្រាវជ្រាវឱ្យមានស្តង់ដាត្រឹមត្រូវ គឺជារឿងដ៏សំខាន់មួយសម្រាប់អ្នកស្រាវជ្រាវ បញ្ញាវន្ត និងនិស្សិតដែលត្រូវធ្វើការស្រាវជ្រាវ។ APA ជាប្រព័ន្ធដ៏សំខាន់មួយដែលត្រូវបានគេទទួលយកជាប្រព័ន្ធសម្រាប់រៀបចំឯកសារស្រាវជ្រាវនៅទូទាំងពិភពលោក។ ហេតុដូចនេះហើយទើបខ្ញុំសម្រេចចងក្រងស្បៀវភៅនេះ។

ស្បៀវភៅនេះមានគោលបំណងជួយឱ្យអ្នកស្រាវជ្រាវ យល់ដឹង និងរៀបចំឯកសារស្រាវជ្រាវឱ្យត្រូវតាម APA 7th edition ដូចជាការរៀបចំឯកសារយោង រៀបចំតារាង និងរូបជាដើម។

ស្បៀវភៅតូចនេះមិនគ្រប់គ្រាន់នោះទេ ហើយប្រាកដណាស់កំហុសឆ្គងនានាប្រាកដជាមានឡើង ទាំងចេតនាក្តី អចេតនាក្តី។ អ្វីដែលអ្នកស្រាវជ្រាវត្រូវធ្វើជានិច្ចនោះគឺពិគ្រោះជាមួយឯកសារដើមនៃ APA ដែលអាចរកបាននៅតាមបណ្ណាល័យសាកលវិទ្យាល័យនានា។ អ្នកស្រាវជ្រាវគ្រាន់តែសង្ឃឹមថាស្បៀវភៅតូចនេះនឹងជួយឱ្យការរៀបចំឯកសារស្រាវជ្រាវរបស់លោកអ្នកបានត្រឹមត្រូវនិងរលូន។ អ្នកនិពន្ធ រីករាយក្នុងការទទួលពាក្យទិទៀន រិះគន់គ្រប់យ៉ាងតាមរយៈបណ្តាញសង្គម

BlueSky: https://bsky.app/profile/meas3.bsky.social

ជាចុងក្រោយសូមជូនពរឱ្យអ្នកអានទាំងអស់ជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខ ពល កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃ អង្គារ ៣កើត ខែភទ្របទ ឆ្នាំម្សាញ់ សប្តស័ក ពស ២៥៦៩

កម្ពុជា, ថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០២៥

មាស (MEAS)

មាតិកា

ទំព័រកម្មសិទ្ធបញ្ញា

អារម្ភកថា

ជំពូក ១ | អំពី APA Style 7th Edition

១.១ តើអ្វីជា APA Style 7th Edition ? 8-11

ជំពូក ២ | របៀបចុះអាគតដ្ឋាន (Citation)

២.១ តើអ្វីជា in-text citation ? 12-15

២.២ ចំណុចសំខាន់ៗក្នុងការចុះអាគតដ្ឋាន 16-23

ជំពូក ៣ | របៀបសរសេរ ឯកសារយោង (Reference)

៣.១ ទំនាក់ទំនងរវាងអាគតដ្ឋាន និង គន្ថនិទ្ទេស 24

៣.២ របៀបសរសេរប្រភេទផ្សេងៗនៃឯកសារយោង 25-43

៣.៣ ការរៀបចំបញ្ជីឯកសារយោង 44-46

៣.៤ ភាពឆកល្វែងមួយចំនួន 47-52

៣.៥ ការច្បាស់រវាងភាពឆកល្វែង 53

ជំពូក ៤ ៖ ស្តង់ដានៃតារាង និង រូប

៤.១ ការរៀបចំតារាង 54-59

៤.២ ការរៀបចំរូប 60-62

Bibliography 63-71

ជំពូក ១
សេចក្តីផ្តើមពី APA Style 7th Edition


APA ជាអក្សរកាត់មកពី American Psychological Association ។ American Psychological Association ជាស្ថាប័នជំនាញរបស់សហរដ្ឋអាមេរិកដែលតំណាងឱ្យចិត្តវិទូទូទាំងប្រទេស ។

APA ជាស្ថាប័នមួយដែលបានបង្កើតនូវ APA Style ដែលជាសំណុំនៃក្បួនច្បាប់សម្រាប់កំណត់ទម្រង់ (Format) នៃការស្រាវជ្រាវវិទ្យាសាស្ត្រ ។ ចាប់តាំងពីថ្ងៃដែល APA Style ប្រសូតឡើង រហូតមកដល់សព្វថ្ងៃ យើងបានឃើញការអភិវឌ្ឍដល់ ជំនាន់ទី ៧ ហើយដែលគេហៅថា APA Style 7th Edition ។


គោលបំណង របស់ APA Style 7th Edition រចនាឡើងក្នុងគោលបំណងធានានូវភាពច្បាស់លាស់ ឯកសណ្ឋានភាព និង ភាពជឿជាក់ នៅក្នុងការស្រាវជ្រាវ ។ APA Style ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅក្នុង មុខវិជ្ជាវិទ្យាសាស្ត្រសង្គម ផ្នែកអប់រំ និង មុខវិជ្ជាផ្សេងៗជាច្រើនទៀត ។

APA បានបោះពុម្ពនូវឯកសារផ្លូវការសម្រាប់ APA Style 7th Edition ដែលជាសេចក្តីណែនាំផ្សេងៗក្នុងការរៀបចំឯកសារស្រាវជ្រាវឱ្យស្របទៅតាមស្តង់ដាកំណត់ ។

រូប ១ ឯកសារផ្លូវការនៃ APA Style 7th Edition



នៅក្នុងជំនាន់ទី ៧ នៃ APA មានសេចក្តីណែនាំចំនួន ១២ជំពូក ស្តីពីធាតុសំខាន់ៗផ្សេងៗទាក់ទងនឹងការសរសេរ និង បោះពុម្ពអត្ថបទស្រាវជ្រាវដូចខាងក្រោម ៖



APA Style មានគ្រប់យ៉ាងសម្រាប់អ្នកស្រាវជ្រាវដើម្បីផលិតបាននូវអត្ថបទស្រាវជ្រាវទៅតាមស្តង់ដា ។ យ៉ាងណាមិញនៅក្នុងស្បៀវភៅនេះយើងនឹងសង្ខេបយកចំណុចសំខាន់ៗប៉ុណ្ណោះជាពិសេសចំណុចទាក់ទងនឹងការចុះអាគតដ្ឋាន ការសរសេរបញ្ជីឯកសារយោង និង ការរៀបចំតារាង និង រូបដើម្បីជួយសម្រួលដល់អ្នកស្រាវជ្រាវ ជាពិសេសនិស្សិតដែលទើបនឹងប្រឡូកក្នុងកិច្ចការស្រាវជ្រាវជាលើកដំបូង ។

ជំពូក ២

របៀបចុះអាគតដ្ឋាន

២.១ | តើអ្វីជា **in-text citation ?**

In-text citation គឺជាទម្រង់មួយនៃការបញ្ជាក់ឯកសារយោង (ជាទូទៅគេប្រើឈ្មោះអ្នកនិពន្ធ និង ឆ្នាំ) នៅក្នុងអត្ថបទរបស់យើង ដើម្បីបង្ហាញពីប្រភពដើមនៃគំនិតដែលយើងលើកឡើង ។

ជាទូទៅអ្នកស្រាវជ្រាវចុះអាគតដ្ឋានក្នុងគោលបំណង ៖

» ផ្តល់កិត្តិគុណចំពោះម្ចាស់គំនិត

» ចៀសវៀងពី “ការលួចចម្លងស្នាដៃ“ (Plagerism)

» បង្កើនទម្ងន់ឱ្យស្នាដៃស្រាវជ្រាវរបស់យើង

» ជួយឱ្យអ្នកអានស្នាដៃរបស់យើងអាចធ្វើការស្រាវជ្រាវបន្ថែមពីឯកសារយោងរបស់យើង

» បង្ហាញពីការប្រតិបត្តខ្ជាប់ខ្ជួនចំពោះច្បាប់កម្មសិទ្ធបញ្ញា

របៀបចុះ in-text citation ដែលគេប្រើប្រាស់ជាទូទៅមានពីររបៀបគឺ ៖ Parenthetical citation និង Narrative citation

Narrative citation ៖ ជាការចុះ citation នៅក្នុងអត្ថបទជាបែបបរិយាយ ដោយ គេប្រើត្រកូលអ្នកនិពន្ធ និង ឆ្នាំដាក់ក្នុងវង់ក្រចក ។

> សិស្សនៅក្នុងក្រុមដែលមានរចនាសម្ព័ន្ធច្បាស់លាស់ បង្ហាញសកម្មភាពជាក្រុមច្រើនជាងសិស្សដែលស្ថិតនៅក្រុមសហការដែលគ្មានរចនាសម្ព័ន្ធជាក់លាក់ (Gillies, 2008) ។

Parenthetical citation ៖ ជាការចុះអាគតដ្ឋាននៅក្នុងវង់ក្រចកខាង ក្នុង ប្រយោគ ឬ ចុងប្រយោគដោយមានធាតុសំខាន់ចំនួនពីរគឺ ៖ ឈ្មោះអ្នកនិពន្ធ (ត្រកូល) និង ឆ្នាំលក្នុងវង់ក្រចកតែមួយ ។

> Gillies (2008) រកឃើញថាសិស្សនៅក្នុងក្រុមដែលមានរចនាសម្ព័ន្ធច្បាស់លាស់ បង្ហាញសកម្មភាពជាក្រុមច្រើនជាងសិស្សដែលនៅក្រុមសហការគ្មានរចនាសម្ព័ន្ធ ។

? តើនៅពេលណាដែលយើងគួរប្រើ Parenthetical Citation?

តើនៅពេលណាដែលយើងគួរប្រើ Narrative Citation?

Parenthetical Citation ៖ ជាទូទៅគេសរសេរបែប Parenthetical Citation នៅពេលដែលយើងចង់សង្កត់ធ្ងន់ ឬ ចង់បង្ហាញពីព័តិមានដែលយើងលើកឡើង ។

ប្រសិនបើនិស្សិតយល់ថា កិច្ចការ (Assignment) ដែលគ្រូឧទ្ទេសដាក់ឱ្យពួកគេធ្វើ គឺមិនចាំបាច់ ឬ គ្មានអត្ថប្រយោជន៍ជួយដល់ការសិក្សា នោះពួកគេនឹងយល់ថាបន្ទុកការងារ (Workload) របស់ពួកគេគឺធ្ងន់ (Chheav et al., 2023)

Narrative Citation ៖ ជាទូទៅគេសរសេរបែប Narrative Citation នៅពេលដែលចង់សង្កត់ធ្ងន់ ឬ ចង់បង្ហាញពីអ្នកនិពន្ធដែលយើងលើកឡើងមក ។ ក្នុងករណីខ្លះអ្នកស្រាវជ្រាវត្រូវការលើកឡើងពីលទ្ធផល ឬ គំនិតរបស់អ្នកស្រាវជ្រាវផ្សេង ៗគ្នា ដើម្បីធ្វើការពិភាក្សាទៅប្រធានបទណាមួយ ។

មានការលើកឡើងផ្សេងគ្នាអំពីដំណកឃ្លានៅនៅខាងមុខ ឬខាងក្រោយសញ្ញាខណ្ឌ។ Thun (2018) បានលើកឡើងថាដំណកឃ្លាមាននាទីញែកសញ្ញារបៈ (។) ឱ្យដាច់ពីតួព្យញ្ជនៈដើម្បីបញ្ចប់ប្រយោគ ឬបញ្ចប់អត្ថបទ (p.72)។ ប៉ុន្តែ Chan (2011) បានបកស្រាយថា សញ្ញាខណ្ឌជាធាតុមួយនៃឃ្លា មានលក្ខណៈដូចជាពាក្យនិមួយៗដែរ ដូចនេះគ្មានដំណកឃ្លាឡើយនៅក្រោយសញ្ញាខណ្ឌ។

ករណីមួយទៀតគឺនៅពេលដែលមានការចុះអាគតដ្ឋានផ្ទួនៗគ្នា អ្នកនិពន្ធ ឬអ្នកស្រាវជ្រាវប្រើប្រាស់ទាំង Narrative និង Parenthetical ពីព្រោះគាត់ចង់ឱ្យអត្ថបទងាយស្រួលអាន ។

២.២ ។ ចំណុចសំខាន់ៗក្នុងការចុះអាគតដ្ឋាន

ក. ចំពោះឯកសារដែលគ្មានឆ្នាំ ឬ ឯកសារកំពុងបោះពុម្ពផ្សាយ

» ពេលខ្លះឯកសារ (ស្បៀវភៅ, របាយការណ៍ស្រាវជ្រាវ ...) មិនបានដាក់ឆ្នាំជាក់លាក់នោះទេ ។ ក្នុងករណីនេះយើងប្រើ “n.d.” នៅក្នុង in-text citation ។

» ការរៀប Algebra tile ដើម្បីរៀបជាចតុកោណដើម្បីដាក់ជាកត្តាមិនងាយស្រួលទេ ហើយគ្រូត្រូវលើកទឹកចិត្តសិស្សឱ្យរៀបរហូតដល់ត្រូវ (Kennard, n.d.) ។

» Kennard (n.d.) លើកឡើងថាការរៀបជាចតុកោណ..... ។

» ករណីមួយទៀតគឺឯកសារដែលមិនទាន់បានបោះពុម្ពចេញមក ប៉ុន្តែកំពុងបោះពុម្ពផ្សាយ ។ ក្នុងករណីនេះយើងប្រើ “in press” ។

» ការរៀនតាមបែបសហការ បានដើរតួនាទីជាស្ពានក្នុងនាំសិស្សឱ្យមានឱកាសក្នុងការជជែក ពិភាក្សា និង សួរគ្នាបានច្រើនជាងមុន ជាហេតុបណ្តាលឱ្យបរិមាណទំនាក់ទំនងគណិតវិទ្យាកើនឡើង (Chum & Sin, in press) ។


» Chum and Sin (in press) បានរៀបរាប់ពីអត្ថប្រយោជន៍.....

๑. ការចុះអាគតដ្ឋានចំពោះកិច្ចការស្រាវជ្រាវដែលមានអ្នកនិពន្ធច្រើន

ពេលអ្នកចាប់ផ្តើមធ្វើការរំលឹកទ្រឹស្តី (Literature review) អ្នកនឹងត្រូវអាន ឯកសារច្រើនប្រភេទ ហើយប្រភេទនិមួយៗមានលក្ខណៈខុសគ្នា ហើយអ្នក នឹងជួបឯកសារដែលមានអ្នកនិពន្ធច្រើននាក់នៅក្នុង ស្បៃវរៅ ឬ អត្ថបទ ស្រាវជ្រាវមួយ ។

» ករណីអ្នកនិពន្ធពីរូប

- Parenthetical : (ត្រកូលអ្នកនិពន្ធទី ១ & ត្រកូលអ្នកនិពន្ធទី ២, ឆ្នាំ)
- Narrative: ត្រកូលអ្នកនិពន្ធទី ១ and ត្រកូលអ្នកនិពន្ធទី ២ (ឆ្នាំ)




Parenthetical ៖ គោលបំណងចម្បងនៃការអប់រំក្នុងសង្គមមូលធននិយមគឺ បន្តបង្កើតហ៊ាន:ក្នុងសង្គម (Bowels & Gintis, 2011) ។

Narrative ៖ Bowel and Gintis (2011) បានលើកឡើងថា គោលបំណង ចម្បងនៃការអប់រំក្នុងសង្គមមូលធននិយមគឺបន្តបង្កើតហ៊ាន:ក្នុងសង្គម ។

» ករណីអ្នកនិពន្ធចាប់ពី ៣ រូបឡើងទៅ

ចំពោះអ្នកនិពន្ធចាប់ពី ៣ រូបឡើងទៅ យើងប្រើ “et al.” ដោយលើកតែអ្នកនិពន្ធដំបូងគេរួចជំនួសអ្នកនិពន្ធបន្ទាប់ដោយប្រើពាក្យ et al. ។



Parmelle et al. (2012) បានឱ្យយោបល់ថា ការរៀបចំថ្នាក់ដើម្បីអនុវត្តវិធីសាស្ត្របង្រៀន TBL ធ្វើយ៉ាងណាឱ្យសិស្សអាចនៅជាបណ្តុំក្រុមតូចៗ ជារង្វង់ក៏បាន នៅក្រឡឹងជុំវិញតុមួយក៏បាន ។

ក្នុងការរៀបចំទីកន្លែងរៀន ដើម្បីអនុវត្ត TBL គ្រូត្រូវធ្វើយ៉ាងណាឱ្យសិស្សអាចផ្តុំគ្នាជារង្វង់ ឬ ជុំគ្នាព័ទ្ធជុំវិញតុក៏បាន (Parmelle et al., 2012) ។

គ. ការចុះអាគតដ្ឋានចំពោះកិច្ចការផ្សេងៗគ្នាច្រើន

» ដើម្បីចុះអាគតដ្ឋានចំពោះកិច្ចការច្រើន យើងត្រូវប្រើសញ្ញា " ; " ដើម្បីញែកកិច្ចការនិមួយៗទៅតាមលំដាប់អក្ខរក្រមសម្រាប់ Parenthetical citation ។

- **អ្នកនិពន្ធ និង ឆ្នាំផ្សេង ៗ គ្នា (អ្នកនិពន្ធឯកសារទី ១, ឆ្នាំ; អ្នកនិពន្ធឯកសារទី ២; .....) ។**

  ឧ៖ ....(Cazden, 2001; Imm & Stylianou, 2012; Measures et al., 1997)

- **ចំពោះកិច្ចការផ្សេងៗគ្នាប៉ុន្តែអ្នកនិពន្ធដូចគ្នា យើងប្រើតែត្រកូលអ្នកនិពន្ធតែម្តងរួចតម្រៀបឆ្នាំតាមលំដាប់ ។**

  ឧ៖ ....(Gillies, 2008, 2014)

- **ចំពោះអ្នកនិពន្ធតែមួយ និង ឆ្នាំតែមួយនៅក្នុងឯកសារផ្សេងគ្នា នោះយើងប្រើអក្សរ a ឬ b ដើម្បីញែកកុំឱ្យច្រឡំគ្នា ។**

  ឧ ៖ ....(Johnson & Johnson, 2008a).....(Johnson & Johnson 2008b)

» **ចំពោះ** Narrative Citation **យើងអាចរៀបតាមលំដាប់ណាក៏បាន ។**

ឧ ៖ ..... Gresham & Shannon (2017), Kazemi and Stipek (2001), Manouchehri (2007), **និង** Manouchehri and John (2006) **បានពិភាក្សាអំពីសារៈសំខាន់នៃទំនាក់ទំនងគណិតវិទ្យាក្នុងថ្នាក់រៀន .... ។**

ឃ. របៀបចុះអាគតដ្ឋានចំពោះកិច្ចការដែលអ្នកនិពន្ធជាក្រុម ឬ ស្ថាប័នមួយ

» ដើម្បីចុះអាគតដ្ឋានចំពោះកិច្ចការដែលអ្នកនិពន្ធជាស្ថាប័ន ឬ ក្រុមមួយ ដែលគ្មានអក្សរកាត់យើងប្រើឈ្មោះស្ថាប័ននោះពេញតែម្តង ។

» ចំពោះស្ថាប័ន ឬ ក្រុមអ្នកនិពន្ធ ដែលមានអក្សរកាត់យើងត្រូវប្រើឈ្មោះពេញរបស់ស្ថាប័ន ឬ ក្រុមនោះដោយដាក់អក្សរកាត់នៅក្នុងដង្កៀបសម្រាប់ការចុះអាគតដ្ឋានលើកទី ១ ក្នុងក្រដាសរបស់យើង ។ ចំពោះការចុះអាគតដ្ឋានលើកទី ២ តទៅ យើងប្រើត្រឹមអក្សរកាត់ប៉ុណ្ណោះ ។

គោលបំណងចម្បងនៃក្របខណ្ឌរអប់រំនៅសិង្ហបុរីគឺ ការដោះស្រាយបញ្ហា និយាយឱ្យចំគឺការប្រើប្រាស់គណិតវិទ្យាដើម្បីដោះស្រាយបញ្ហានានាក្នុងជីវិតពិត (Ministry of Education [MoE], 2012) ។

ចុះអាគតដ្ឋានដំបូងបំផុត

ក្របខណ្ឌនេះផ្តោតសំខាន់ទៅលើ ការស្វែងយល់បញ្ញត្តិ ការអភិវឌ្ឍជំនាញ និង ដំណើរការគិតគណិតវិទ្យា (MoE, 2012) ។

ចាប់ពីលើកទី ២ ក្នុងអត្ថបទ

ង. ការស្រង់ផ្នែកណាមួយក្នុងឯកសារទាំងស្រុង

✎ ករណីសម្រង់ខ្លី (តិចជាង ៤០ពាក្យ)

របៀបចុះអាគតដ្ឋានចំពោះសម្រង់ផ្នែកណាមួយទាំងស្រុង

Narrative citation: ត្រកូលអ្នកនិពន្ធ (ឆ្នាំ) “.....“ (p...)
Parenthetical citation: “.....“ (ត្រកូល, ឆ្នាំ, p...)
*ករណីទំព័រច្រើនប្រើអក្សរ pp..

ឧទាហរណ៏ៈ

“ការដូរពាក្យ សរសេរតាមសូត្រ ទៅជា សរសេរតាមអាន ស្អីគេនោះ ជាការបញ្ជាក់ឱ្យឃើញនូវភាពស្ទើរភ្លើងរបស់អ្នកបង្កើត ដែលយើងមិនត្រូវទទួលយក” (Thun, 2018, p. 252) ។

Thun (2018) បានពណិនាអំពីភាពខុសឆ្គងក្នុងការប្រើពាក្យសរសេរតាមអានថា “ការដូរពាក្យ សរសេរតាមសូត្រ ទៅជា សរសេរតាមអាន ស្អីគេនោះជាការបញ្ជាក់ឱ្យឃើញនូវភាពស្ទើរភ្លើងរបស់អ្នកបង្កើត ដែលយើងមិនត្រូវទទួលយក” (p.252)។

ករណីសម្រង់លើសពី៤០ពាក្យ

ចំពោះសម្រង់លើសពី៤០ពាក្យ អាគតដ្ឋានមានលក្ខណៈមួយចំនួនដូចជា៖

» មិនប្រើសញ្ញាអញ្ជប្រកាស “.....“ ដើម្បីគាបសម្តីនិយាយឡើយ ។

» ត្រូវចូលបន្ទាត់ 0.5in ហើយដកឃ្លា 2.0 (double space) ។


» ទម្រង់នៃ citation ដូចសម្រង់សម្តីខ្លីដែរ។

ឧទាហរណ៏៖

Metropolitan Center for Urban Education (2008) defined culturally responsive classroom management:

> Culturally Responsive Classroom Management (CRCM) is an approach to running classrooms with all children, [not simply for racial/ethnic minority children] in a culturally responsive way. More than a set of strategies or practices, CRCM is a pedagogical approach that guides the management decisions that teachers make. It is a natural extension of culturally responsive teaching which uses students' backgrounds, rendering of social experiences, prior knowledge, and learning styles in daily lessons. (p.2)

ប្រភេទអ្នកនិពន្ធ	Narrative citation	Parenthetical citation
អ្នកនិពន្ធពីររូប	(Balta & Sarac, 2016)	Balta amd Sarac (2016)
អ្នកនិពន្ធបីរូបឡើង	(Cohen et al., 2018)	Cohen et al. (2018)
ក្រុម ឬ ស្ថាប័ន 1. លើកទី ១ 2. ចាប់ពីលើកទី ២	1. (ក្រសួងអប់រំយុវជន និង កីឡា [អយក], 2018) 2. (អយក, 2018)	1. ក្រសួងអប់រំយុវជន និង កីឡា (អយក, 2018) 2. អយក (2018)
1. គ្មានអ្នកនិពន្ធ 2. គ្មានឆ្នាំ 3. កំពុងបោះពុម្ព	1. (10 effective question techniques, 2024) 2. (Lee, n.d.) 3. (Nhim, in press)	1. 10 effective question techniques (2024) 2. Lee (n.d.) 3. Nhim (in press)
អ្នកនិពន្ធផ្សេងគ្នា ៗ	(Haidet et al., 2015; Louati et al., 2014; Michaelsen & Sweet, 2008)	Michaelsen and Sweet (2008), Louati et al. (2014) និង Haidet et al. (2015)...
ការស្រង់ផ្នែកណាមួយនៅក្នុងឯកសារ	(Greene, 2007, p. 20)	Greene (2007) បានលើកឡើងថាការស្រាវជ្រាវរបៀបចម្រុះជា ....(p. 42)



ជំពូក ៣
របៀបសរសេរបញ្ជីឯកសារយោង

៣.១ ៖ ទំនាក់ទំនងរវាងអាគតដ្ឋាន និង គន្ថនិទ្ទេស

នៅពេលដែលយើងធ្វើការចុះអាគតដ្ឋាននូវស្នាដៃណាមួយនៅក្នុងឯកសារស្រាវជ្រាវរបស់យើង នោះយើងត្រូវដាក់នៅក្នុងបញ្ជីឯកសារយោង ឬ គន្ថនិទ្ទេសនូវព័ត៌មានចាំបាច់សម្រាប់សម្គាល់ និង សម្រាប់ការស្រាវជ្រាវបន្តផងដែរ ។

នៅក្នុងអត្ថបទស្រាវជ្រាវ

តួនាទីរបស់គ្រូបង្រៀននៅក្នុងវិធីសាស្ត្រ Communicative Language Learning គឺសម្រួលដល់ទំនាក់ទំនងក្នុងថ្នាក់រៀន (Richards & Rodgers, 2014) ។

នៅក្នុងគន្ថនិទ្ទេស

Richards, J.C., & Rodgers, T.S. (2014). *Approaches and methods in language teaching* (3rd ed.). Cambridge University Press.

៣.២ ៖ របៀបសរសេរប្រភេទផ្សេងៗនៃឯកសារយោង

ឯកសារយោងអាចយកចេញពីប្រភពជាច្រើនដូចជា ៖

» សៀវភៅ (book)

» អត្ថបទស្រាវជ្រាវ (Journal Article)


» Book Chapter

» គេហទំព័រ (Website)

» និង ប្រភពឯកសារដ៏ទៃទៀត ។

Book	Book Chapter
Journal Article	Website

ក | អត្ថបទស្រាវជ្រាវ (Journal article)



ត្រកូលអ្នកនិពន្ធ, ឈ្មោះជាអក្សរកាត់

ចំណងជើងអត្ថបទ (sentence case)


Hatice, C. (2019). Explaining the concept and operations of integer in primary school mathematics teaching opposite model sample. *Universal Journal of Educational Research*, *7*(2), 365-370. https://doi.org/10.13189/ujer.2019.070208

ទំព័រ

Volume (អក្សរទ្រេត) Issue នៅក្នុងវង់ក្រចក អក្សរធម្មតា

DOI

» ឈ្មោះ Journal
» អក្សរទ្រេត

ធាតុសំខាន់ៗ	ការពណិនា
អ្នកនិពន្ធ	យើងប្រើនាមត្រកូល និង ឈ្មោះជាអ្នកកាត់៖ ✎ James Smith >> Smith, J. 
ឆ្នាំ	ឆ្នាំដែលអត្ថបទបោះពុម្ពផ្សាយ
ចំណងជើងអត្ថបទ	ចំណងជើងជា sentence case មានន័យថា យើងសរសេរអក្សរធំនៅខាងដើមប្រយោគ ។
ឈ្មោះ Journal	ឈ្មោះ Journal ត្រូវសរសេរជាអក្សរទ្រេត
Volume និង Issue	Volume ជាវ៉ុល ឯ issue ជាលេខសម្គាល់ទស្សនាវដ្តីស្រាវជ្រាវ ។
ទំព័រ	ជាទំព័ររបស់អត្ថបទនោះនៅក្នុង Jornal (ទស្សនាវដ្តី)
DOI	ជាតំណរភ្ជាប់សម្រាប់សម្គាល់ឯកសារស្រាវជ្រាវ ។ ✎ ឯកសារស្រាវជ្រាវខ្លះគ្មាន DOI ✎ ឯកសារស្រាវជ្រាវខ្លះមាន Website ជំនួស DOI

នៅក្នុង in-text citation, យើងប្រើ et al. សម្រាប់ស្នាដៃដែលមានអ្នកស្រាវជ្រាវចាប់ពី ៣ រូប ។ ប៉ុន្តែនៅក្នុងគន្ថនិទ្ទេស យើងត្រូវបង្ហាញគ្រប់ឈ្មោះអ្នកស្រាវជ្រាវ ។

Journal of Universal Computer Science, vol. 30, no. 6 (2024), 720-757
submitted: 25/5/2023, accepted: 13/1/2024, appeared: 28/6/2024 CC BY-ND 4.0

Digital Transformation of Public Services in a Startup-Based Environment: Job Perceptions, Relationships, Potentialities and Restrictions

George Marsicano
(University of Brasilia (UnB), Brasilia–DF, Brazil
https://orcid.org/0000-0001-9212-9124, georgemarsicano@unb.br)

Edna Dias Canedo
(University of Brasilia (UnB), Brasilia–DF, Brazil
https://orcid.org/0000-0002-2159-339X, ednacanedo@unb.br)

Glauco V. Pedrosa
(University of Brasilia (UnB), Brasilia–DF, Brazil
https://orcid.org/0000-0001-5573-6830, glauco.pedrosa@unb.br)

Cristiane S. Ramos
(University of Brasilia (UnB), Brasilia–DF, Brazil
https://orcid.org/0000-0002-6235-5590, cristianesramos@unb.br)

Rejane M. da C. Figueiredo
(University of Brasilia (UnB), Brasilia–DF, Brazil
https://orcid.org/0000-0001-8243-7924, rejanecosta@unb.br)

Marsicano, G., Canedo, E.D., Pedrosa, G.V., Ramos, C.S., & Figueiredo, R.M.C. (2024). Digital transformation of public services in a startup-based environment: Job perceptions, relationships, potentialities and restrictions. *JUCS - Journal of Universal Computer Science 30*(6): 720-757. https://doi.org/10.3897/jucs.106979

๒ | សៀវភៅ (Book)

ធាតុសំខាន់ៗនៃស្បៀវភៅមាន ៖

» អ្នកនិពន្ធ ៖ ត្រកូលអ្នកនិពន្ធ និង ឈ្មោះជាអក្សរកាត់ ។

» ឆ្នាំបោះពុម្ពផ្សាយ

» ចំណងជើងស្បៀវភៅ (និង ចំណងជើងរងបើមាន) ៖ ចំណងជើង និង ចំណងជើងរងត្រូវប្រើអក្សរទ្រេត (italic) និង សរសេរជា sentence case ។


» ចំនួនលើកនៃការបោះពុម្ព-edition (1st ed., 2nd e.d.,....)

» ស្ថាប័នបោះពុម្ព (Publisher)

អ្នកនិពន្ធ (ឆ្នាំ). ចំណងជើងស្បៀវភៅ (ចំនួនលើកនៃការបោះពុម្ពបើមាន) . ស្ថាប័នបោះពុម្ពផ្សាយ.

Author (Year). *Book title* (ed.). Publisher.

ចូរពិនិត្យមើលពីព័ត៌មានសំខាន់ៗដែលត្រូវយកចេញពីផ្នែកខាងមុខ (Front Matter) នៃស្បៀវភៅ From STEM to STEAM ដើម្បីសរសេរឯកសារយោងតាមរូបនៅទំព័របន្ទាប់ ។




នេះគឺជា**គម្របស្បៃវែកៅ** ក្នុងនេះអាចឱ្យយើងដឹងពតិមានមួយចំនួនដូចជា ៖

» អ្នកនិពន្ធ


» ចំណងជើងស្បៃវែកៅ

» ពេលខ្លះនៅលើគម្របបង្ហាញ ចំនួនលើកនៃការបោះពុម្ព




» ទំព័រនេះជា **Half title page**

» ព័តិមាននៅក្នុងទំព័រនេះមានបង្ហាញត្រឹមចំណងជើង និង ចំនួនលើកនៃការបោះពុម្ពប៉ុណ្ណោះ ។




» នេះជា **Title Page** នៅក្នុងទំព័រនេះមានពត៌មានសំខាន់ៗដូចជា៖

- ចំណងជើង & ចំណងជើងរង
- ចំនួនលើក/ដងនៃការបោះពុម្ព
- អ្នកនិពន្ធ
- ស្ថាប័នបោះពុម្ពផ្សាយ



» នេះជា **Copyright Page** ដែលមានព័ត៌មានលម្អិតពីស្បៀវភៅ ។

» តាមព័ត៌មានខាងលើយើងអាចសរសេរឯកសារយោងបាន ៖



✎ ករណីដែលត្រូវប្រើអក្សរធំនៅកណ្តាលប្រយោគ

យើងដឹងថាចំពោះ Sentence Case គឺសរសេរអក្សរធំនៅខាងមុខប្រយោគ ប៉ុន្តែមានករណីមួយចំនួនទៀតដែលយើងអាចប្រើអក្សរធំនៅក្នុងប្រយោគ ៖

» អសាធារណនាម ៖ ចំពោះអសាធារណនាម យើងអាចប្រើអក្សរធំបាន ។

Chandler, D.P. (2018). *A history of Cambodia* (4th ed.). Taylor & Francis.

» អក្សរកាត់ ៖ ចំពោះអក្សរកាត់យើងអាចសរសេរអក្សរធំបាន ។

Pieratt, J. (2020). *Keep it real with PBL, elementary : a practical guide for planning project-based learning. Corwin.*

» Hyphenated Compound ៖ ប្រើអក្សរធំចំពោះពាក្យផ្សំគ្នាដោយសញ្ញា (–) បើជាពាក្យទីមួយនៅខាងមុខប្រយោគ ជាអសាធារណនាម ឬ ជាអក្សរកាត់ ។

Tuttle, D.W., & Tuttle, N.R. (2004). *Self-Esteem and adjusting with blindness: The process of responding to life's demands* (3rd ed.). *Charles C Thomas Pub Ltd.*

តើ សៀវភៅ (Book) និង Book Chapter ខុសគ្នាដូចម្តេច ?

Book	Book Chapter
ចំពោះសៀវភៅ ជំពូក ឬ ផ្នែកផ្សេងៗ គ្នាមិនមានអ្នកនិពន្ធផ្សេងគ្នាទេ។ សៀវភៅមានអ្នកនិពន្ធរួម ។	ជំពូក ឬ ផ្នែក និមួយៗនៅក្នុង Book Chapter មានអ្នកនិពន្ធផ្សេងៗគ្នា ។ ជំពូកផ្សេងៗគ្នាទាំងនោះមានទំនាក់ទំនងជាមួយប្រធានបទរួមនៃសៀវភៅ ។
សៀវភៅអាចមាន Editor ឬ ក៏គ្មាន Editor ។	Book Chapter មាន Editor នៅគម្របខាងមុខ ។

ដើម្បីដឹងថាឯកសារដែលយើងអានជា Book ឬ Book Chapter យើងអាចមើលទៅពីរចំណុច ៖

1. គម្រប និង title page ៖ ប្រសិនបើជា Book Chapter នោះនៅលើគម្រប ឬ title page មិនបង្ហាញឈ្មោះអ្នកនិពន្ធទេ ពោលគឺបង្ហាញត្រឹម Editor(s) ប៉ុណ្ណោះ ។
2. មាតិកា (content) ៖ មាតិកានៃ Book Chapter នឹងបង្ហាញឈ្មោះអ្នកនិពន្ធផ្សេងៗគ្នាចំពោះផ្នែកផ្សេងៗគ្នា ។ ចូរសង្កេតមើលឧទាហរណ៍នៅទំព័របន្ទាប់ ៖

Piaget, Vygotsky and beyond

Future issues for developmental psychology and education

Edited by

ចំណងជើងរួម

Leslie Smith, Julie Dockrell and Peter Tomlinson

ឈ្មោះ Editor

ឆ្នាំ និង
អ្នកបោះពុម្ព

First published 1997
by Routledge
11 New Fetter Lane, London EC4P 4EE

Simultaneously published in the USA and Canada
by Routledge
29 West 35th Street, New York, NY 10001

Routledge is an imprint of the Taylor & Francis Group

This edition published in the Taylor & Francis e-Library, 2005.

"To purchase your own copy of this or any of Taylor & Francis or Routledge's collection of thousands of eBooks please go to www.eBookstore.tandf.co.uk."

© 1997 Selection and editorial matter, Leslie Smith, Julie Dockrell and Peter Tomlinson; individual chapters © the contributors

All rights reserved. No part of this book may be reprinted or reproduced or utilised in any form or by any electronic, mechanical, or other means, now known or hereafter invented, including photocopying and recording, or in any information storage or retrieval system, without permission in writing from the publishers.

British Library Cataloguing in Publication Data
A catalogue record for this book is available from the British Library

Contents

List of figures vi

List of tables vii

List of contributors viii

Editorial note ix

Introduction 1
Leslie Smith, Julie Dockrell and Peter Tomlinson

Part 1 Educational intervention and teaching

1 Educational implementation and teaching: 'School knowledge' and psychological theory 15
Michael Beveridge

2 Piaget and Vygotsky: A necessary marriage for effective educational intervention 27
Michael Shayer

3 Psychological theory that 'works' in the classroom 47
Kathy Sylva

Part 2 Social collaboration and learning

4 Psychological development as a social process 52
Gerard Duveen

5 Revisiting young Jean Piaget in Neuchâtel among his partners in learning 70
Anne-Nelly Perret-Clermont

6 Piaget, Vygotsky and the social dimension 92
Gerry P.T.Finn

ចំណាំ ៖ ផ្នែកនៅក្នុងរង្វង់ពណិក្រហមជាចំណងជើង Book Chapter ឯផ្នែកចំណែកផ្នែកដែលគូលបន្ទាត់ខាងក្រោមជាឈ្មោះអ្នកនិពន្ធ ។ យើងឃើញថាមានអ្នកនិពន្ធផ្សេងៗគ្នាជាច្រើនដែលបានចូលរួមចំណែកជា Book Chapter មួយ ។

ធាតុសំខាន់ៗនៅក្នុង Book Chapter

ធាតុសំខាន់ៗ	ការពណិនា
អ្នកនិពន្ធ	យើងប្រើនាមត្រកូល និង ឈ្មោះជាអ្នកកាត់៖ ✎ Kathy Sylva >> Sylva, K.
ឆ្នាំ	ឆ្នាំដែលអត្ថបទបោះពុម្ពផ្សាយ
ចំណងជើងអត្ថបទ	ចំណងជើងជា sentence case (មិនទ្រេត) ។
ឈ្មោះ Editor	ឈ្មោះជាអក្សរកាត់ . ត្រកូល ✎ Leslie Smith >> L. Smith ✎ Julie Dockrell >> J. Dockrell ✎ Peter Tomilson >> P. Tomilson
ឈ្មោះស្បៀវភៅ	ឈ្មោះរួមនៃ Book Chapter (ទ្រេត)
ទំព័រ	ជាទំព័ររបស់អត្ថបទនោះ (pp.)
Publisher	ឈ្មោះស្ថាប័នបោះពុម្ព

អ្នកនិពន្ធ (ឆ្នាំ). ចំណងជើងអត្ថបទ (មិនទ្រេត). In Editor (Ed (s)*), ចំណងជើងស្បៀវភៅ (pp. ទំព័រ). publisher.

តាមរយៈ Book Chapter ខាងលើយើងអាចសរសេរឯកសារយោងបាន ៖

អ្នកនិពន្ធ ឆ្នាំ ចំណងជើងអត្ថបទ

Sylva, K. (1997). Psychological theory that 'work' in the class room. In L. Smith, J. Dockrell, & P. Tomilson (Eds.), *Piaget, Vygotsky and beyond: Future issue for developmen -tal psychology and education* (pp. 47-50). Routledge.

Editors

ចំណងជើងស្បៀវភៅ (ទ្រេត)

ទំព័រអត្ថបទ

Publisher

In-text citation: Sylva (1997) / ...(Sylva, 1997)

ឧទាហរណ៍បន្ថែម៖

Ng, K.E.D., Lee, H.N., & Safii, L. (2021). Facilitation of stu dents' metacognition: Some insights gleaned from mathe matics classrooms in Singapore secondary schools. In B. Kaur & Y.H. Leong (Eds.), *Mathematics instructional prac -tices in Singapore secondary schools* (pp 105-122). Spring -er.

In-text citation: Ng et al. (2021) / ... (Ng et al., 2021)


ឃ| គេហទំព័រ (Website)

ធាតុសំខាន់ៗនៅក្នុងគេហទំព័រមាន ៖

» អ្នកនិពន្ធ
» ខែ ឆ្នាំ
» ចំណងជើង
» ឈ្មោះ Website
» តំណងភ្ជាប់ (link)

ចំណាំ៖ នៅក្នុង APA 6th Ed. មុននឹងដាក់ដំណភ្ជាប់ គេមានពាក្យថា retrieved, (ខែ ថ្ងៃ, ឆ្នាំ), (រួចដាក់តំណភ្ជាប់)។ APA 7th គ្មានទៀតទេ។

អ្នកនិពន្ធ (ឆ្នាំ, ខែ). ចំណងជើងអត្ថបទ (ទ្រេត). ឈ្មោះ website. URL (តំណភ្ជាប់)



Jackson, D.F. (2025, August). *Guiding students to learn math facts-without timed tests*. Edutopia. https://www.edutopia.org/article/guiding-students-learn-math-facts

កំណត់សម្គាល់

គេហទំព័រខ្លះគ្មានអ្នកនិពន្ធទេ។ ក្នុងករណីនេះ យើងយកចំណងជើងអត្ថបទមកដាក់ជំនួសកន្លែងអ្នកនិពន្ធ។



Malnutrition. (2023, June 13). World Health Organization. https://www.who.int/news-room/fact-sheets/detail/malnutrition

In-text citation: Malnutrition (2023)/...(Malnutrition, 2023)

+ រៀបសាយខ្លះគ្មានដាក់ថ្ងៃខែដាក់លាក់ ។ ក្នុងករណីនេះយើងអាចដាក់ n.d ជំនួសកន្លែងឆ្នាំដូចនឹងអត្ថបទស្រាវជ្រាវដែរ។

+ សូមប្រុងប្រយ័ត្ននៅពេល ធ្វើការដកស្រង់អត្ថន័យពីគេហទំព័រដើម្បីយោងនៅក្នុងកិច្ចការស្រាវជ្រាវ ព្រោះថារៀបសាយខ្លះគ្មានទិន្នន័យ ឬខ្លឹមសារដាក់លាក់ដើម្បីគាំទ្រអត្ថបទស្រាវជ្រាវនោះទេ។ ជួនកាលគោលបំណងនៃរៀបសាយរបស់គេគឺដើម្បីពាណិជ្ជកម្មប៉ុណ្ណោះ។

ង| ការសរសេរឯកសារយោងចំពោះភាសាផ្សេង

តាមក្បួនរបស់ APA 7 យើងត្រូវសរសេរឯកសារយោងក្រៅពីភាសាអង់គ្លេស ដោយគោរពតាមគោលការណ៍ខាងក្រោម ៖

» ប្រសិនបើឯកសារនោះសរសេរនៅក្នុងភាសាដែលប្រើអក្ខរក្រមឡាតាំង ដូចជា បារាំង ហូឡង់ ជាដើម យើងសរសេរឈ្មោះអ្នកនិពន្ធ ឆ្នាំ និង ចំណងជើងឯកសារនោះជាភាសាដើម គ្រាន់តែបកប្រែឈ្មោះអត្ថបទ ឬ ឯកសារនោះជាភាសាអង់គ្លេសដាក់ក្នុងដង្កៀបជាការស្រេច ។

» គោលបំណងនៃការបកប្រែជាភាសាអង់គ្លេសគឺដើម្បីឱ្យអ្នកអានដឹងថា អត្ថបទនោះនិយាយអំពីអ្វី ។

ឧទាហរណ៏ ៖

García, J. I. (2020). La influencia de la motivación en el apren dizaje de idiomas [The influence of motivation on language learning]. Revista de Educación, 45(2), 123-140. https://doi.org/10.1007/s12345-020-00321-4

អត្ថបទដើមជាភាសាអេស្ប៉ាញ បកប្រែចំណងជើងជាភាសាអង់គ្លេស។

» ករណីទី ២ ៖ ប្រសិនបើឯកសារនោះជាភាសាបរទេសដែលប្រើអក្ខរក្រមខុសពីអក្សរឡាតាំង យើងត្រូវ ប្រែអក្សរទាំងនោះជាអក្សរឡាតាំងសិន (Romanization) ។

» ឧទាហរណ៍ ៖ ការសរសេរចំពោះឯកសារយោងចំពោះភាសាចិនដោយបកប្រែជាឡាតាំងដោយប្រព័ន្ធ Pinyin ។

Li, W. (2022). Jìshù duì jiàoyù gǎigé de yǐngxiǎng [The impact of technology on educational reform]. *Zhōng guó Jiàoyù Xuébào [Chinese Journal of Education]*, *15*(4), 34–50. https://doi.org/10.12345/cedu.2022.015

» ការបកប្រែជាឡាតាំងនេះមិនសមស្របគ្រប់ករណីទេ ។ តាមក្បួន APA អ្នកនិពន្ធមានសិទ្ធក្នុងការសម្រេចថាតើគួរបកប្រែជាឡាតាំងឬទេ ។

Tanaka, H., & Yamada, K. (2021). 学習者の自律性が教育成果に及ぼす影響 [The impact of learner autonomy on educational outcomes]. *Journal of Japanese Education Studies*, *28*(3), 89-105. https://doi.org/10.1080/12345678.2021.9876543

អត្ថបទដើមជាភាសាជប៉ុន (មិនប្រើអក្សរឡាតាំង) មិនបកប្រែជាឡាតាំងទេ ត្រឹមបកប្រែចំណងជើងជាភាសាអង់គ្លេស។

» ចំពោះភាសាខ្មែររបស់យើង យើងអាចការបកប្រែចំណងភាសាឡាតាំងមិនអាចសមស្របគ្រប់ករណីទេ ។ ដូចនេះយើងអាចបកជាភាសាឡាតាំងត្រឹមអ្នកនិពន្ធរួចទុកចំណងជើងជាភាសាខ្មែរដដែល រួចហើយយើងបកប្រែជាភាសាអង់គ្លេសនៅក្នុងដង្កៀប ។

» ប្រព័ន្ធនេះត្រូវបានសម្រួលយកមកប្រើប្រាស់ ដោយនាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នៃក្រសួងអប់រំយុវជន និង កីឡា ។ តាមយោបល់ផ្ទាល់ខ្លួនរបស់ខ្ញុំ ប្រព័ន្ធនៃការសរសេរឯកសារយោងនេះគួរតែត្រូវបានប្រើប្រាស់ទូលំទូលាយដើម្បីឱ្យមានឯកភាពគ្នា ។

ឧទាហរណ៍ ៖

Heng, S. (2025). តើពិន្ទុគណិតវិទ្យារបស់គរុសិស្សមានឥទ្ធិពលទៅលើទំនុកចិត្តក្នុងការបង្រៀនរបស់ពួកគេដែរឬទេ? [Do student teachers' math score affect their confidence in teaching?]. *Cambodian Journal of Education and STEM*, *3*(1), 14-44. https://doi.org/10.62219/cjes.2025312

អ្នកនិពន្ធ ហេង សីហា ទៅជា Seiha Heng (Heng, S.) ហើយចំណងជើងជាភាសាខ្មែរត្រូវបកជាភាសាអង់គ្លេសផងដែរ។

៣.៣ | ការរៀបចំបញ្ជីឯកសារយោង

ចំណុចសំខាន់ៗមួយចំនួនក្នុងការរៀបចំបញ្ជីឯកសារយោង ៖

» ឯកសារយោងត្រូវរៀបតាមលំដាប់អក្ខរក្រម (A-Z) ។ មួយវិញទៀត ឈ្មោះដែលខ្លីជាត្រូវនៅខាងលើឈ្មោះដែលវែងជាងប្រសិនបើឈ្មោះទាំងពីរមានលំដាប់អក្ខរក្រមដូចគ្នា ។

Mazini, J.V. (2020).

Mazinisa, A. (2020).

» ចំពោះ APA គ្មានការចុះបង់លេខរៀង ឬ ចំណុច (Bullet Point) នោះទេ ។ យើងប្រើត្រឹម Hangling indent (0.5 in) ប៉ុណ្ណោះ ។

» ឯកសារផ្សេងគ្នាដែលមានឆ្នាំដូចគ្នាហើយរៀបរៀងឡើងដោយអ្នកនិពន្ធតែម្នាក់ ត្រូវប្រើអក្សរ a, b ដើម្បីសម្គាល់ ។

Chum, P. (2023a)...

Chum, P. (2023b)...

Chum, P. (2023c)...

» ចំពោះឯកសារដែលមានឆ្នាំផ្សេងគ្នាពីអ្នកនិពន្ធតែម្នាក់ហើយឆ្នាំផ្សេងគ្នា យើងរៀបតាមលំដាប់ឆ្នាំពីឆ្នាំចាស់ ទៅ ឆ្នាំថ្មី ។

Jamie, C. (1999)

Jamie, C. (2000)

Jamie, C. (2002)

Jamie, C. (2021)



ឧទាហរណ៍ៈ គន្ធនិទ្ទេស

Aronson, E., Blaney, N., Stephan, C., Sikes, J., & Snapp, M. (1978). *The jigsaw classroom.* Sage Publications.

Caulfield, J. (2023, June 22). *How to do thematic analysis | step-by-step guide & examples.* Scribbr. Retrieved August 12, 2024, from https://www.scribbr.com/methodology/thematic-analysis/

Deutsch, M. (1962). Cooperation and trust: Some theoretical notes. In M. R. Jones (Ed.), *Nebraska Symposium on Motivation* (pp. 275-319). University of Nebraska Press.

Manouchehri, A. (2007). *Inquiry-Discourse Mathematics Instruction. The Mathematics Teacher*, *101*(4), 290-300. https://doi.org/10.5951/MT.101.4.0290

Manouchehri, A., & John, D. S. (2006). From Classroom Discussions to Group Discourse. *The Mathematics Tacher, 99*(8), 544-551. https://doi.org/10.5951/MT.99.8.0544

Ministry of Education Youth and Sport (2018a). កម្មវិធីសិក្សាលម្អិតរូបវិទ្យាសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ [Physic curriculum for lower secondary level].

Ministry of Education Youth and Sport (2018b). គោលនយោបាយស្តីពីការអប់រំរួមបញ្ចូល [Inclusive education policy].

Sfard, A. (2008). *Thinking as communicating: Human development, the growth of discourses, and mathematizing*. Cambridge University Press. https://doi.org/10.1017/CBO9780511499944

Sfard, A. (2012). Introduction: Developing mathematical discourse-some insights from communicational research. *International Journal of Educational Research*, *51*, 1-9. https://doi.org/10.1016/j.ijer.2011.12.013

Zhang, Y. (2010). Cooperative language learning and foreign language learning and teaching. *Journal of Language Teaching and Research, 1*(1), 81-83. https://doi.org/10.4304/jltr.1.1.81-83

៣.៩ | តារាងកន្លែងមួយចំនួន

កំហុស៖ អត្ថបទផ្សេងគ្នា អ្នកនិពន្ធតែមួយឆ្នាំបោះពុម្ពដូចគ្នា ធ្វើឱ្យអ្នកអានច្រឡំ។

Ministry of Education, Youth and Sport. (2018). *កម្មវិធីសិក្សាលម្អិតមុខវិទ្យាវិទ្យាសាស្ត្រសម្រាប់កម្រិតបឋមសិក្សា* [Science curriculum for primary school].

Ministry of Education, Youth and Sport. (2018). *គោលនយោបាយស្តីពីការអប់រំបរិយាបន្ន* [Inclusive education policy].

ដំណោះស្រាយ៖ ប្រើអក្សរ a b ដាក់នៅជាប់ឆ្នាំដើម្បីបង្ហាញភាពភ័ន្តច្រឡំ ។

Ministry of Education, Youth and Sport. (2018a). *កម្មវិធីសិក្សាលម្អិតមុខវិទ្យាវិទ្យាសាស្ត្រសម្រាប់កម្រិតបឋមសិក្សា* [Science curriculum for primary school].

Ministry of Education, Youth and Sport. (2018b). *គោលនយោបាយស្តីពីការអប់រំបរិយាបន្ន* [Inclusive education policy].

កំហុស ៖ ប្រើប្រាស់អក្សរកាត់នៅក្នុងបញ្ជីឯកសារយោង ធ្វើឱ្យបាត់បង់ភាពច្បាស់លាស់ និង ជាក់លាក់នៃឯកសារយោង ។

MoEYS. (2019). *Cambodia's education 2030 roadmap*.

NCTM. (2014). *Principles to actions: Ensuring mathematics success for all.*

ដំណោះស្រាយ ៖ ប្រើប្រាស់ឈ្មោះពេញ ។

Ministry of Education, Youth and Sport. (2019). *Cambodia's education 2030 roadmap*.

National Council of Teachers of Mathematics. *(2014). Principles to actions: Ensuring mathematics success for all.*

ចំណាំ ៖ យើងមិនត្រូវប្រើអក្សរកាត់នោះទេ នៅពេលដែលយើងសរសេរនៅក្នុងបញ្ជីឯកសារយោង ទោះជាឯកសារយោងនោះត្រូវបានទទួលស្គាល់ជាទូលំទូលាយយ៉ាងណាក៏ដោយ ។

» UN. (2023). .... >> United Nation. (2023). ....

» WHO. (2021). ... >> WHO. (2021). .....

កំហុសលើទម្រង់នៃការសរសេរ ដូចជា៖ ខុសទម្រង់ឈ្មោះអ្នកនិពន្ធ, ការប្រើប្រាស់អក្សរធំ, និង ការប្រើប្រាស់អក្សរទ្រេត ។

ឧទាហរណ៏ ៖

Asha K. Jitendra and Kathryn Hoff. (1996). The Effects of Schema-Based Instruction on the Mathematical Word-Problem Solving Performance of Students with Learning Disabilities. Journal of Learning Disabilities, 29 (4), 422-431.

Jitendra, K.A., & Hoff, K. (1996). The effects of schema-based instruction on the mathematical word-problem solving performance of students with learning disabilities. *Journal of Learning Disabilities*, *29* (4), 422-431.

ក្រៅពីកំហុសខាងលើ នៅមានកំហុសមួយចំនួនទៀតដែលទាក់ទងនឹងប្រព័ន្ធផ្សេងៗទៀតដែលមិនមែនជា APA Style 7th Edition ហើយត្រូវបានអ្នកសិក្សាច្រឡំចម្លង (Copy) យកមកដាក់ជាឯកសារយោងដោយមិនបានត្រួតពិនិត្យ ។

ឧទាហរណ៏ ៖ MLA 9th Edition

..... (Musti-Rao and Haydon 92) (In-text citation)

Musti-Rao, Shobana, and Todd Haydon. "Strategies to Increase Behavior-Specific Teacher Praise in an Inclusive Environment." *Intervention in School and Clinic*, vol. 47, no. 2, 2011, pp. 91-97. Sage Journals, https://doi.org/10.1177/1053451211414187.

ឧទាហរណ៏ ៖ IEEE Style

នៅក្នុងការស្រាវជ្រាវ .....[1] (In-text citation)

[1] S. Musti-Rao and T. Haydon, "Strategies to Increase Behavior-Specific Teacher Praise in an Inclusive Environment," Intervention in School and Clinic, vol. 47, no. 2, pp. 91-97, Jul. 2011, doi: https://doi.org/10.1177/1053451211414187.

ឧទាហរណ៏ ៖ Vancouver Style

.....ការស្រាវជ្រាវ (1).... (In-text citation)


1. Musti-Rao S, Haydon T. Strategies to increase behavior-specific teacher praise in an inclusive environment. Intervention in School and Clinic. 2011 Jul 29;47(2):91-97. doi:10.1177/1053451211414187

ឧទាហរណ៏ ៖ Chigago Style (Author-date format)

..... (Musti-Rao and Haydon 2011) (In-text citation)

Musti-Rao, Shobana, and Todd Haydon. "Strategies to Increase Behavior-Specific Teacher Praise in an Inclusive Environment." *Intervention in School and Clinic* 47, no. 2 (July 29, 2011): 91-97. https://doi.org/10.1177/1053451211414187.

នេះគ្រាន់ជាឧទាហរណ៏មួយចំនួនប៉ុណ្ណោះ ដោយហេតុថាមានប្រព័ន្ធជាច្រើនផ្សេងទៀតក្រៅពី APA ដែលត្រូវបានប្រើប្រាស់ក្នុងការបោះពុម្ពផ្សាយដែលទាមទារឱ្យអ្នកស្រាវជ្រាវមានការប្រុងប្រយ័ត្នជាអតិបរមា ។



Other style other than APA.

៣.៩ | ការចៀសវាងឯភាពឆកល្វែង

កត្តាសំខាន់បំផុតដើម្បីចៀសវាងភាពឆកល្វែងក្នុងការសរសេរឯកសារយោង យើងត្រូវពិគ្រោះជាមួយឯកសារដើម្បីឱ្យប្រាកដថាយើងមិនប្រព្រឹត្តកំហុសនោះទេ ។

ឯកសារដែលយើងត្រូវពិគ្រោះគឺ ៖

- ស្បៃវ៉ែកផ្លូវការរបស់ American Psychological Association : ស្បៃវ៉ែកនេះមានកម្រាស់ប្រហែល ៧00+ ទំព័រ ។ ស្បៃវ៉ែកនេះមានគ្រប់យ៉ាងដែលយើងត្រូវការដើម្បីឱ្យឯកសាររបស់យើងស្របទៅតាម APA Style 7th Edition ។
- ក្រៅពីស្បៃវ៉ែកផ្លូវការ យើងអាចស្វែងរកបទបង្ហាញ (slide) ឬ ស្បៃវ៉ែកសង្ខេបស្តីពី APA Style ដែលឯកសារទាំងនោះស្រង់ចំណុចសំខាន់ៗចេញពីស្បៃវ៉ែកដើម ។
- ឯកសារនេះក៏អាចជាឯកសារសង្ខេបមួយដែលយើងអាចពឹងពាក់បានដើម្បីរៀបចំឯកសារយើងឱ្យស្របទៅនឹង APA Style 7th Edition ។ ព្រោះថាឯកសារជាខេមរភាសានៅខ្សត់នៅឡើយ ។

ក្រៅការពិនិត្យល្អិតល្អន់ យើងអាចប្រើប្រាស់បច្ចេកវិទ្យា ផ្សេងៗដើម្បីជួយដល់ការចុះអាគតដ្ឋាន និង រៀបចំបញ្ជីឯកសារយោងផងដែរ ។ បច្ចេកវិទ្យាទាំងនោះមានដូចជា ៖ គេហទំព័រផ្សេងៗ និង កម្មវិធីផ្សេងៗទៀត ។ សូមបញ្ជាក់ថាយើងត្រូវមានចំណេះដឹងទាក់ទងទៅនឹងAPA Style ផងដែរ ព្រោះថាទោះជា គេហទំព័រ និង កម្មវិធីកុំព្យូទ័រក៏ត្រូវការយើងជាអ្នកបញ្ចូលទិន្នន័យ និង ពិនិត្យថែមផងដែរ ។

ជំពូក ៤

ស្តង់ដានៃតារាង និង រូប

៤.១| ការរៀបចំតារាង

ក. ធាតុសំខាន់ៗនៃតារាង

ធាតុសំខាន់នៅក្នុងតារាងមាន ៖

» **លេខនៃតារាង (Table Number)** ៖ យើងត្រូវប្រើលេខអារ៉ាប់ដើម្បីដាក់លេខតារាង (ឧទាហរណ៍ ៖ តារាង 1, តារាង 2....) ។ ចំពោះលេខតារាងត្រូវប្រើអក្សរដិត (Bold) ។

» **ចំណងជើងតារាង (Table title)** ៖ ចំណងជើងតារាងត្រូវប្រើអក្សរទ្រេត ហើយចុះបន្ទាត់ពីក្រោមលេខនៃតារាង (double space) ។ ត្រូវប្រាកដថាចំណងជើងតារាង មិនត្រូវទុលំទូលាយពេក និង លម្អិតពេកទេ ។

» **ក្បាលនៃតារាង** ៖ ក្បាលនៃតារាងមានលក្ខណៈផ្សេងៗគ្នាទៅតាមតារាង ក្នុងនោះមាន Stub heading ដែលជាក្បាលពិពណ៌នាផ្នែកខាងឆ្វេងបំផុតនៃតារាង ។ Stub heading ពិពណ៌តារាងខាងឆ្វេងបំផុត ប៉ុន្តែយើងត្រូវដាក់វានៅចំកណ្តាល ។

» **តួនៃតារាង (Body)** ៖ តួនៃតារាងគឺជាជួរដេក និង ជួរឈរនៃតារាង ។ នៅក្នុងតារាង ខាងឆ្វេងដៃបង្អស់ត្រូវដាក់ Left align ។ ចំពោះព័ត៌មានទូទៅ ក្រៅពីផ្នែកខាងឆ្វេងបង្អស់ គឺត្រូវដាក់ចំកណ្តាល centered align ។

» **កំណត់សម្គាល់** (Note) ៖ គេដាក់កំណត់សម្គាល់នៅពីក្រោមតារាងដើម្បី

បន្ថែមព័ត៌មានទាក់ទងនឹងតារាងរបស់យើង ។ តារាងខ្លះអាចមានកំណត់សម្គាល់ ហើយតារាងខ្លះក៏គ្មានកំណត់សម្គាល់នោះដែរ ។

តារាង 30 ← លេខតារាង

ឧទាហរណ៍អំពីតារាងក្នុងទម្រង់ APA ← ចំណងជើង

តេប៉ាតឺម៉ង់	ប្រេកង់		%
	ចំនួន	ធៀប	
គណិតវិទ្យា	30	.3	30
ចិត្ត-គរុកោសល្យ	10	.1	10
ស្រាវជ្រាវ-បណ្ណាល័យ	15	.15	15
ភាសាបរទេស	10	.1	10
ព័ត៌មានវិទ្យា	20	.2	20
សិក្សាសង្គម	5	.05	5
វិទ្យាសាស្ត្រ	10	.1	10
សរុប	100	1	100

ក្បាលតារាង

ផ្នែកតារាង

Note. ទិន្នន័យនេះប្រឌិតឡើងដើម្បីធ្វើជាឧទាហរណ៍ប៉ុណ្ណោះ។

๑. ចំណុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់

» **ចំពោះចំនួនទសភាគ** ៖ ចំនួនទសភាគដូចជា 0.33 ត្រូវសរសេរជាទម្រង់ .33 ។ ចំពោះទសភាគដែលគ្មានសូន្យពីខាងមុខ យើងសរសេរជាធម្មតា ។

» **ភាពច្បាស់លាស់** ៖ យើងមិនត្រូវដាក់គ្រប់ទិន្នន័យចូលតារាងនោះទេ ។ ទិន្នន័យដែលគេអាចគណនាបានដោយងាយ មិនចាំបាច់ដាក់ចូលតារាងទេ ។

» **អាគតដ្ឋាននៅក្នុងតារាង** ៖ នៅក្នុងតារាង ប្រសិនបើយើងត្រូវធ្វើអាគតដ្ឋានចំពោះអ្នកនិពន្ធពីររូប យើងត្រូវប្រើពាក្យ “and” ជំនួសឱ្យសញ្ញា & ។

» **អក្សរកាត់** ៖ នៅក្នុងតារាងយើងប្រើអក្សរកាត់ស្តង់ដា និង និម្មិតសញ្ញាសម្រាប់ស្ថិតិដូចជា ៖ M=មធ្យម, SD=គម្លាតស្តង់ដា, df=ដឺក្រេសេរី ជាដើម ។ យើងក៏ប្រើអក្សរក្រិកដូចជា $\rho\ \sigma\ \Sigma\ \lambda\ \beta\ \alpha\ \omega\ \theta$ ជាដើម ។

» **ចំពោះការចាក់ពណ៌ (shading)** ៖ សូមចៀសវៀងការប្រើប្រាស់ពណ៌នៅក្នុងតារាង ។ ប្រសិនយើងត្រូវចាំបាច់ចាក់ពណ៌នៅក្នុងតារាងដោយខានពុំបាន សូមពន្យល់ពីមូលហេតុនៅកន្លែងកំណត់សម្គាល់ខាងក្រោមតារាង ។

» **ការប្រើ Border** ៖ ជាទូទៅ ប្រើបន្ទាត់តែ Border ដែលនៅខាងលើ និងខាងក្រោមនៃតារាងប៉ុណ្ណោះ និងក្រោមក្បាលតារាង។ យើងក៏ប្រើ border ដើម្បីនៅកន្លែងសង្ខេប ឬ ជាកន្លែងសរុបទិន្នន័យ ឬសម្រាប់ញែកផ្នែកនិមួយ ៗនៃតារាង។ **ចូរកុំប្រើបន្ទាត់បញ្ឈរ និងកុំប្រើបន្ទាត់ដេកនៅគ្រប់កាឡានៃទិន្នន័យ។**

តារាង 4

តម្រែតម្រង់ពហុអថេរសម្រាប់ព្យាករណ៍ម៉ោងសិក្សាដ៏មានអត្ថន័យសរុប (n=2051)

អថេរ	B	SE B	β
ទីកន្លែងស្នាក់នៅ	0.48	0.1	0.12***
ប្រភេទនៃការចុះឈ្មោះសិក្សា	0.5	0.17	0.07**
ភាសាកំណើត	0.13	0.1	0.03
ឆ្នាំសិក្សា	0.03	0.05	0.01
សប្តាហ៍	0.3	0.09	0.07***

Note. ទិន្នន័យនេះយកមកពីអត្ថបទរបស់ Scrully, J. & Kerr, R. (2014). Student workload and assessment: Strategies to manage expectations and inform curriculum development. *Accounting Education: An International Journal*, *23*(5), 443-466.

$*p < 0.05, **p < 0.01, ***p < 0.001$

តារាង 3

Independent sample t-test of psychological well-being of male and female staff (Issahaku et al., 2020)

ភេទ	N	Mean	SD	df	t-value	sig (2-tailed)
ប្រុស	178	43.5	7.23	289	2.244	.035
ស្រី	113	42.5	5.29			

ជាទូទៅសម្រាប់ ការឡោនដំបូងតួដំបូងត្រូវដាក់ខាងឆ្វេង (Left indent) ដោយមិនដាក់កណ្តាលឡើយ ប៉ុន្តែករណីនេះ យើងអាចដាក់កណ្តាលបាន ព្រោះថាអក្សរក្នុងនោះ (ប្រុស, ស្រី) ខ្លីពេកហេតុនេះ តាម APA យើងអាចដាក់កណ្តាលបាន។

+ ចំណាំ...

ជារឿយៗនៅក្នុងកាលិកបត្រស្រាវជ្រាវ យើងនឹងឃើញទម្រង់នៃតារាង រាង ប្លែកពី APA បន្តិច ទោះជាកាលិកបត្រទាំងនោះគោរពតាម APA Style ក៏ដោយ។

ការសម្រួលខុសពី APA Style អាចមកពីមូលហេតុដូចជា ដើម្បីចំនេញកន្លែង ឬដើម្បីឱ្យស្អាត ឬជាគោលការណ៍របស់កាលិកបត្រនិមួយៗ។ ទោះជាមូលហេតុណាក៍ដោយ នេះមិនមែនជាកំហុសទេ ហើយនៅពេលដែលយើងគ្រោងបោះពុម្ពនៅកាលិកបត្រណាមួយយើងត្រូវធ្វើតាមគម្រូរបស់កាលិកបត្រជាក់លាក់និមួយៗ។

Table 6. f Square

	INTG	PEOUG	PUG	SS
Gamification Quality (GQ)		0.065		
Instructor Characteristic (IC)		**0.451**		
Intention to use Gamification (INTG)				
Perceived Ease of Use Gamification (PEOUG)	0.092		**0.597**	**0.407**
Perceived Usefulness (PUG)	**0.015**			0.060
Student Satisfaction (SS)	**0.325**			
Technology Anxiety (TA)		0.037	0.022	

Musyaffi, A. M., Sulistyowati, W. A., Wolor, C. W., & Sasmi, A. A. (2022). Game-based learning sustainability during social distance: The role of gamification quality. Eu ropean *Journal of Educational Research*, *11*(3), 1289-1302. https://doi.org/10.12973/eu-jer.11.3.1289

៤.២ | ការរៀបចំរូប (Preparing Figure)

» **រូប (figure)** មានច្រើនប្រភេទផ្សេងៗដូចជា ក្រាហ្វ ដ្យាក្រាម រូបថត រូបភាព ជាដើម..។

» **លេខ** ៖ ដំបូងយើងត្រូវដាក់លេខឱ្យរូបរបស់យើង ដោយប្រើអក្សរដិត (ឧទាហរណ៍ ៖ **Figure 1, Figure 2**, **រូប 1, រូប 2**...) ។

» **ចំណងជើងរូប** ៖ នៅពីក្រោមលេខយើងដាក់ចំណងជើងរូប (ដកឃ្លា 2pt) ដោយ*ប្រើអក្សរទ្រេត* ។

» **រូបភាព** ៖ រូបភាពអាចជាក្រាហ្វ រូបភាព ឬ រូបថតជាដើម ។

- រូបត្រូវតែច្បាស់ ងាយស្រួលក្នុងការយល់ ។
- អក្សរដែលនៅក្នុងរូបត្រូវតែច្បាស់លាស់ ហើយទំហំអាចពីចន្លោះពី 8 pt ទៅ 14 pt ។
- ចំណុចសំខាន់ៗនៃក្រាបត្រូវតែលេចធ្លោ ។ ឧទាហរណ៍ ៖ ខ្សែកាច់នៅលើក្រាបត្រូវតែដិតជាង អ័ក្សអាប់ស៊ីស និង អ័ក្សអរដោនេ ។


» **Legend** ៖ Legend ជាតំណាងផ្សេងៗនៅក្នុងរូប។

» **កំណត់ចំណាំ** ៖ កំណត់សម្គាល់មានបីប្រភេទ ដូចជា ៖ កំណត់សម្គាល់ទូទៅ កំណត់សម្គាល់ជាក់លាក់ និង កំណត់សម្គាល់ទាក់ទងនឹងប្រូបាប៊ីលីតេ ។ គេដាក់កំណត់សម្គាល់នៅពីក្រោមរូបដើម្បីបន្ថែមព័ត៌មានទាក់ទងនឹងរូបដែលពិបាកយល់ ឬ ព័ត៌មានបន្ថែម ។ រូបខ្លះអាចមានកំណត់សម្គាល់ ហើយរូបខ្លះក៏គ្មានកំណត់សម្គាល់នោះដែរ ។

APA STYLE 7th EDITION MEAS


Figure 5 លេខរូប

Students' perception of personal characteristics ចំណងជើងរូប



Note. ទិន្នន័យពី Chheav et al. (2023) ទាក់ទងទៅនឹងទំហំកិច្ចការរបស់និស្សិត។

ឧទាហរណ៍....



Note. ចំណងជើងនៃអត្ថបទស្រាវជ្រាវមិនប្រើ Sentence case ដូច APA 7 ប្រហែលជាទម្រង់របស់កាលិកបត្រស្រាវជ្រាវ។

យកពីៈ Hieng, S., & Sondom, T. (2022). Questioning technique in learning English grammar: A case of primary education student teacher at Battambang teacher education college. *Action Research Series*, *2*, 1-29.

Bibliogarphy

American Psychological Association (2019). *Publication Manual of the American Psychological Association*. American Psychological Association (APA).

Aronson, E., Blaney, N., Stephan, C., Sikes, J., & Snapp, M. (1978). *The jigsaw classroom.* Sage Publications.

Balta, N. & Sarac, H. (2016). The effect of 7E learning cycle on learning in science teaching: A meta-analysis study. *European Journal of Educational Research*, *5*(2), 61-72. https://doi.org/10.12973/eu-jer.5.2.61

Cazden, C. B. (2001). *Classroom discourse: The language of teaching and learning* (2nd ed.). Helnemann.

Caulfield, J. (2023, June 22). *How to do thematic analysis | step-by-step guide & examples.* Scribbr. https://www.scribbr.com/methodology/thematic-analysis/

Chan, S. (2011). *អន្តរកម្មនិយមៈ ដំណេីរឃ្លាក្នុងភាសាខ្មែរ [Interactionism : Spacing in Khmer language].*

Chandler, D.P. (2018). *A history of Cambodia* (4th ed.). Taylor & Francis.

Chheav, S., Chum, P., Leng, V., Lai, P., Kimleang, T., & Duo, E. (2023). Year-three students' perception toward workload at Institute of Foreign Language. [unpublished bachelor thesis]

Chum, P. & Sin, S. (2024). *ការអនុវត្តការរៀនតាមបែបសហការដើម្បីបង្កើនទំនាក់ទំនងគណិតវិទ្យារបស់សិស្សថ្នាក់ទី៨* [Implementing co operative leanring to eight grade students' mathematical discourse][conference presentation]. Fourth Research Conference, Phnom Penh, Cambodia.

Deutsch, M. (1962). Cooperation and trust: Some theoretical notes. In M. R. Jones (Ed.), *Nebraska Symposium on Motivation* (pp. 275-319). University of Nebraska Press.

García, J. I. (2020). La influencia de la motivación en el apren dizaje de idiomas [The influence of motivation on language learning]. Revista de Educación, 45(2), 123-140. https://doi.org/10.1007/s12345-020-00321-4

Gillies, R. M. (2008). The effects of cooperative learning on junior high school students' behaviors, discourse and learning during a science-based learning activity. *School Psychology International*, *29* (3), 328-347. https://doi.org/10.1177/0143034308093673

Gillies, R. M. (2014). Cooperative learning: Developments in research. *International Journal of Educational Psychology*, *3*(2), 125-140.

Greene, J. C. (2007). *Mixed methods in social inquiry*. Jossey-Bass.

Gresham, G., & Shannon, T. (2017). Building mathematics discourse in students. *Teaching Children Mathematics*, *23*(6), 360-366.

Haidet, P., Kubitz, K., & McCormack, W.T. (2014). Analysis of team based learning literature: TBL comes of age. *J Excel Coll Teach*, *25* (3-4), 303-333.

Hatice, C. (2019). Explaining the concept and operations of integer in primary school mathematics teaching opposite model sample. *Universal Journal of Educational Research*, *7*(2), 365-370. https://doi.org/10.13189/ujer.2019.070208

Heng, S. (2025). តើពិន្ទុគណិតវិទ្យារបស់គរុសិស្សមានឥទ្ធិពលទៅលើទំនុកចិត្តក្នុងការបង្រៀនរបស់ពួកគេដែរឬទេ? [Do student teachers' math score affect their confidence in teaching?]. *Cambodian Journal of Education and STEM*, *3*(1), 14-44. https://doi.org/10.62219/cjes.2025312

Hieng, S., & Sondom, T. (2022). Questioning technique in learning English grammar: A case of primary education student teacher at Battambang teacher education college. *Action Research Series*, *2*, 1-29.

Imm, K., & Stylianou, D. A. (2012). Talking mathematically: An analysis of discourse communities. *The Journal of Mathematical Behavior*, *31*, 130-148.

Issakhu, J., Anthony, N.K., Bakiri, Y. D. (2020). Impact of work life balance on the psychological wellbeing of employee in the University of Cape Coast. Journal of Psychology and Behavioral Science, 8(1), 18-19. https://doi.org/10.15640/jpbs.v8n1a1

Jackson, D.F. (2025, August). *Guiding students to learn math facts-without timed tests*. Edutopia. https://www.edutopia.org/article/guiding-students-learn-math-facts

Jitendra, K.A., & Hoff, K. (1996). The effects of schema-based instruction on the mathematical word-problem solving performance of students with learning disabilities. *Journal of Learning Disabilities*, *29*(4), 422-431.

Johnson, D. W., & Johnson, R. T. (2008). Cooperative learning: Successful integration of theory, research, and practice. *The Annual Report of Educational Psychology in Japan*, *47*, 4-8.

Kennerd, V. (n.d.). *Algebra tiles learning sequence*.

Kazemi, E., & Stipek, D. (2001). Promoting conceptual thinking in four upper-elementary mathematics classroom. *School*

Journal, *102*(1), 59-80. https://doi.org/10.1086/499693

Lee, K. (n.d.). Blockchain applications in supply chain management. *Frontiers in Blockchain*.

Li, W. (2022). Jìshù duì jiàoyù gǎigé de yǐngxiǎng [The impact of technology on educational reform]. *Zhōng guó Jiàoyù Xuébào [Chinese Journal of Education]*, *15*(4), 34–50. https://doi.org/10.12345/cedu.2022.015

Louati, K., Bettaieb, L., & Derbel, L. (2014). *Team-based leaning in mathematics courses* [conference papaer]. SEFI 42nd Annual Conference, Birmingham, UK.

Malnutrition. (2023, June 13). World Health Organization. https://www.who.int/news-room/fact-sheets/detail/malnutrition

Manouchehri, A. (2007). *Inquiry-Discourse Mathematics Instruction. The Mathematics Teacher*, *101*(4), 290-300. https://doi.org/10.5951/MT.101.4.0290

Manouchehri, A., & John, D. S. (2006). From Classroom Discussions to Group Discourse. *The Mathematics Tacher, 99*(8), 544-551. https://doi.org/10.5951/MT.99.8.0544

Marsicano, G., Canedo, E.D., Pedrosa, G.V., Ramos, C.S., & Figueiredo, R.M.C. (2024). Digital transformation of

public services in a startup-based environment: Job perceptions, relationships, potentialities and restrictions. *JUCS - Journal of Universal Computer Science 30*(6): 720-757. https://doi.org/10.3897jucs.106979

Measures, E., Quell, C., & Wells, G. (1997). A sociocultural perspective on classroom discourse. In B. Davies & D. Corson (Eds.), *Encyclopedia of Language and Education Volume 3: Oral discourse and education*.

Metropolitan Center for Urban Education (2008). *Culturally responsive classroom management strategies*. New York University. Michaelson, L. & Sweet, M. (2008). The essential elements of

team-based learning. *New Directions for Teaching and Learning* 2008(116), 7 - 27. https://doi.org/10.1002/tl.330

Ministry of Education (2012). Mathematics syllabus: Primary one to six. *Curriculum Planning and Development Division.*

Ministry of Education Youth and Sport (2018a). កម្មវិធីសិក្សាលម្អិតរូបវិទ្យាសម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ [Physic curric-ulum for lower secondary level].

Ministry of Education Youth and Sport (2018b). គោលនយោបាយស្តីពីការអប់រំបរិយាបន្ន [Inclusive education policy].

Ministry of Education, Youth and Sport. (2019). *Cambodia's education 2030 roadmap*.

Musti-Rao, S. & Haydon, T. (2011). Strategies to increase behavior-specific teacher praise in an inclusive environment. *Intervention in School and Clinic*, *47*(2), 91-97.https://doi.org/10.1177/1053451211414187.

Musyaffi, A. M., Sulistyowati, W. A., Wolor, C. W., & Sasmi, A. A. (2022). Game-based learning sustainability during social distance: The role of gamification quality. European *Journal of Educational Research*, *11*(3), 1289-1302. https://doi.org/10.12973/eu-jer.11.3.1289

National Council of Teachers of Mathematics. *(2014). Principles to actions: Ensuring mathematics success for all.*

Ng, K.E.D., Lee, H.N., & Safii, L. (2021). Facilitation of students' metacognition: Some insights gleaned from mathematics classrooms in Singapore secondary schools. In B. Kaur & Y.H. Leong (Eds.), *Mathematics instructional practices in Singapore secondary schools* (pp. 105-122). Springer.

Parmelee, D., Michaelsen, L. K., Cook, S., & Hudes, P. D. (2012). Team-Based Learning: A practical guide: Amee guide no. 65. *Medical Teacher*, *34*(5). https://doi.org/10.3109/0142159x.2012.651179

Pieratt, J. (2020). *Keep it real with PBL, elementary : a practical guide for planning project-based learning. Corwin.*

Richards, J.C., & Rodgers, T.S. (2014). *Approaches and methods in language teaching* (3rd ed.). Cambridge University Press.

Scrully, J. & Kerr, R. (2014). Student workload and assessment: Strategies to manage expectations and inform curriculum development. *Accounting Education: An International Journal*, *23*(5), 443-466.

Sfard, A. (2008). *Thinking as communicating: Human develop ment, the growth of discourses, and mathematiz -ing*. Cambridge University Press. https://doi.org/10.1017/CBO9780511499944

Sfard, A. (2012). Introduction: Developing mathematical dis course-some insights from communicational research. *In -ternational Journal of Educational Research*, *51*, 1-9. https://doi.org/10.1016/j.ijer.2011.12.013

Sousa, D. A., & Pilecki, T. (2018). *From STEM to STEAM: Brain-Compatible strategies and lessons that integrate the arts.* Corwin.

Sylva, K. (1997). Psychological theory that 'work' in the class room. In L. Smith, J. Dockrell, & P. Tomilson (Eds.), *Piaget, Vygotsky and beyond: Future issue for develop -mental psychology and education* (pp. 47-50). Routledge.

Thun, H. (2018). *វេយ្យាករណ៍ជួនណាត [Choun Nath's Grammar]* (2nd ed.). Khmer Books.

Tuttle, D.W., & Tuttle, N.R. (2004). *Self-Esteem and adjusting with blindness: The process of responding to life's demands* (3rd ed.). Charles C Thomas Pub Ltd.

Tanaka, H., & Yamada, K. (2021). 学習者の自律性が教育成果に及ぼす影響 [The impact of learner autonomy on educational outcomes]. *Journal of Japanese Education Studies*, *28*(3), 89-105. https://doi.org/10.1080/12345678.2021.9876543

Zhang, Y. (2010). Cooperative language learning and foreign lan guage learning and teaching. *Journal of Language Teaching and Research, 1*(1), 81-83. https://doi.org/10.4304/jltr.1.1.81-83

